ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៥៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងឃុំសំបូរ ជាមួយឃុំវង្គនៈ នៃស្រុកសំបូរ ខេត្តក្រចេះ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- ព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- ព្រះរាជក្រមលេខ នស/រកម/១០១៧/០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងឃុំសំបូរ ជាមួយឃុំវ៉ឌ្ឍនៈ នៃស្រុកសំបូរ ខេត្តក្រចេះ ដោយកាត់យកភូមិកោះសំ ពីឃុំសំបូរ មកឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ឃុំវ៉ឌ្ឍនៈ។

ផ្អែកតាមការកែសម្រួលនេះ ព្រំប្រទល់រដ្ឋបាលរវាងឃុំសំបូរ ជាមួយឃុំវ៉ឌ្ឍនៈ នៃស្រុកសំបូរ ខេត្តក្រចេះ ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងឃុំសំបូរ ជាមួយឃុំវ៉ឌ្ឍនៈ នៃស្រុកសំបូរ ខេត្តក្រចេះ ត្រូវចូលជាធរមានសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិទី៥ ស្របតាមខ្លឹមសារមាត្រា ១៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សាខេត្តក្រចេះ គណៈអភិបាលខេត្តក្រចេះ ក្រុមប្រឹក្សាស្រុកសំបូរ គណៈអភិបាលស្រុកសំបូរ ក្រុមប្រឹក្សាឃុំសំបូរ និងក្រុមប្រឹក្សាឃុំវ៉ឌ្ឍនៈ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១២ កើត ខែ ស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៤
-រាជកិច្ច
-ឯកសារកាលប្បវត្តិ

រដ្ឋបាលខេត្តក្រចេះ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីខេត្តក្រចេះ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## ផែនទីកែសម្រួលព្រំប្រទល់រដ្ឋបាលរវាង ឃុំចង្រ្កង: ជាមួយឃុំសំបូរ

## ដោយកាត់យកភូមិកោះសំ ពីឃុំសំបូរ មកអោយស្ថិតក្រោមការគ្រប់គ្រងរបស់ឃុំចង្រ្កង: ស្រុកសំបូរ ខេត្តក្រចេះ

ផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ......១៥៥......អនក្រ.បក ចុះថ្ងៃ..សុក្រ.១២កើត..ខែ.....ស្រាពណ៍.........ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥ ត្រូវនឹងថ្ងៃទី...២០........ខែ..សីហា........ឆ្នាំ២០២១




អ្នកគូស
ក្រចេះ, ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០២១
មន្ត្រីលេខា

លេខ............ ឃ សប
បានឃើញ និងពិនិត្យត្រឹមត្រូវ
មេឃុំ

លេខ............
បានឃើញ និងពិនិត្យត្រឹមត្រូវ
មេឃុំ
យុន គីម

លេខ...០៥៥ប.......
បានឃើញ និង ឯកភាព
ថ្ងៃ............ ត្រីស័ក ព.ស ២៥៦៥
ក្រចេះ, ថ្ងៃទី......ខែ......ឆ្នាំ ២០២១

ស ខេង

លេខ............
បានឃើញ និង យល់ព្រម
ថ្ងៃ............ ត្រីស័ក ព.ស ២៥៦៥
ក្រចេះ, ថ្ងៃទី ០២ ខែ............ឆ្នាំ ២០២១
អភិបាលខេត្ត

វ៉ា ថន

លេខ............
បានឃើញ និង ពិនិត្យត្រឹមត្រូវ
ថ្ងៃ............ ត្រីស័ក ព.ស ២៥៦៥
ក្រចេះ, ថ្ងៃទី ១៣ ខែ............ឆ្នាំ ២០២១
ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម

បណ្ឌិត.កៅ ម៉ាឌីឡែន

លេខ............
បានឃើញ និង ពិនិត្យត្រឹមត្រូវ
ថ្ងៃ............ ត្រីស័ក ព.ស ២៥៦៥
ក្រចេះ, ថ្ងៃទី............ខែ............ឆ្នាំ ២០២១
អភិបាលស្រុក

សូម សវិត

លេខ............
បានឃើញ និង ពិនិត្យត្រឹមត្រូវ
ថ្ងៃ............ ត្រីស័ក ព.ស ២៥៦៥
ក្រចេះ, ថ្ងៃទី............ខែ............ឆ្នាំ ២០២១
ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម